01387730

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
17 / 02 / 2017
ម៉ោង (Time/Heure) : 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, សហចៅក្រមស៊ើបអង្កេត

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើបន្ទាន់លើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំការអនុញ្ញាតផ្តល់ឯកសារសម្ងាត់ពីសំណុំរឿង ០០២ ទៅឲ្យមេធាវីការពារក្តី មាស មុត ក្នុងសំណុំរឿង ០០៣

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសម្ងាត់ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ សុំការអនុញ្ញាតផ្តល់ឯកសារសម្ងាត់ពីសំណុំរឿង ០០២ ទៅឱ្យមេធាវីការពារក្តី មាស មុត ក្នុងសំណុំរឿង ០០៣ (ឯកសារ E442/3 "សំណើសុំ")។ អនុលោមតាមនីតិវិធីដែលបានកំណត់ក្នុងដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំការអនុញ្ញាតដាក់បង្ហាញឯកសារដែលលើកឡើងនៅក្នុងឧបសម្ព័ន្ធសម្ងាត់ ខ (ឯកសារ E442/ 3.2) ដោយផ្អែកលើមូលដ្ឋានថា មេធាវីការពារក្តី មាស មុត ចាំបាច់ត្រូវពិនិត្យមើលសម្ភារៈទាំងនេះ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសុំដាក់ឯកសារទៅក្នុងសំណុំរឿង ០០៣ (ឯកសារ E442/2 កថាខណ្ឌ ២-៣)។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំការ

អនុញ្ញាតនេះជាបន្ទាន់ ដោយសារតែកាលបរិច្ឆេទស្នើសុំកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ របស់សហព្រះរាជអាជ្ញាគឺនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៧។ គ្មានភាគីណាមួយដាក់សារណាតបទៅនឹងសំណើសុំនេះទេ។

២. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា អង្គជំនុំជម្រះធ្លាប់បានយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិរួចមកហើយ ក្នុងការផ្តល់ការអនុញ្ញាតដល់ក្រុមមេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ និង ០០៤ ឱ្យចូលពិនិត្យមើលឯកសារមួយចំនួនដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធនឹងការស្វែងរកការពិតនៅក្នុងសំណុំរឿងទាំងនោះ (ឯកសារ E442/1 កថាខណ្ឌ ២-៣, ឯកសារ E442/2/1 កថាខណ្ឌ ៣)។ បន្ទាប់ពីបានពិនិត្យមើលបញ្ជីឯកសារនៅក្នុងឧបសម្ព័ន្ធ ខ អង្គជំនុំជម្រះពុំជំទាស់ទៅនឹងការផ្តល់ឯកសារសម្ងាត់ពីសំណុំរឿង ០០២ ទាំងនេះទៅឱ្យមេធាវីការពារក្តី មាស មុត ទេ។

៣. ហេតុនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំនេះ និងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអន្តរជាតិផ្តល់សំណៅអេឡិចត្រូនិកនៃឯកសារនៅក្នុងឧបសម្ព័ន្ធសម្ងាត់ ខ (ឯកសារ E442/3.2) ទៅឱ្យមេធាវីការពារក្តី មាស មុត។ អង្គជំនុំជម្រះរម្លឹកថា ឯកសារទាំងនេះជាឯកសារសម្ងាត់ ហើយត្រូវរក្សាភាពសម្ងាត់របស់ឯកសារទាំងនេះដូចដើម។

៤. អនុស្សរណៈនេះគឺចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E442/3។